**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៤៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ឯកសណ្ឋានគោរមងារផ្លូវការរបស់អ្នកឧកញ៉ា និងឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

### ជំពូកទី១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ត្រូវបានបង្កើតឯកសណ្ឋានគោរមងារផ្លូវការជូនអ្នកឧកញ៉ា និងឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២ .—**

ឯកសណ្ឋាន សញ្ញាស័ក្តិ មេដាយ និងបន្ទោងខ្សែក របស់អ្នកឧកញ៉ា និងឧកញ៉ា ត្រូវបានប្រើប្រាស់ក្នុងពេលចូលរួមពិធីបុណ្យជាតិ បុណ្យប្រពៃណីជាតិ និងពិធីផ្លូវការផ្សេងៗ ។

## ជំពូកទី២

## ឯកសណ្ឋាន

**មាត្រា ៣ .—**

ឯកសណ្ឋានគោរមងារផ្លូវការរបស់អ្នកឧកញ៉ា និងឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវស្លៀកពាក់ទៅតាមគោរមងារដែលទទួលបានជា អ្នកឧកញ៉ា និងឧកញ៉ា ។

### ផ្នែកទី១

### ឯកសណ្ឋានគោរមងារ អ្នកឧកញ៉ា

**មាត្រា ៤ .—**

ឯកសណ្ឋានគោរមងារផ្លូវការរបស់អ្នកឧកញ៉ា ត្រូវបានកំណត់ដូចខាងក្រោម ៖

**១-ចំពោះបុរស**

**ក-អាវ ៖**

- អាវកុត កត្រង់ ដៃវែងពណ៌ស មានប៉ូលបកបិតទាំងសងខាង ផែកខ្នងខាងក្រោមទាំងសងខាងមិនជីបស្មា ជីបខ្នង និងមានឡេវមុខរូបព្រះរាជសង្ហារពណ៌មាសចំនួនប្រាំពីរ និងមានទំហំ២៤មីលីម៉ែត្រ។ អាវនេះ មានហោប៉ៅខាងមុខដេរបង្កប់ចំនួនបួន នៅខាងលើពីរ និងខាងក្រោមពីរ។ ហោប៉ៅពីរខាងលើ មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធសម្រាប់ដាក់ឡេវដែលមានរូបព្រះរាជសង្ហារពណ៌មាសទំហំ១៨មីលីម៉ែត្រ ។ ហោប៉ៅពីរខាងក្រោមដេរបង្កប់ ដែលហោប៉ៅម្ខាងៗ មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធដាក់ឡេវរូបព្រះរាជសង្ហារពណ៌មាស ទំហំ២១មីលីម៉ែត្រ ។
- នៅលើស្មាទាំងសងខាង មានបំពាក់**សញ្ញាស័ក្តិស្មា** ដូចមានចែងក្នុងចំណុច១ នៃមាត្រា៧ ។
- ចុង កអាវទាំងសងខាង មានបំពាក់**សញ្ញាស័ក្តិលើចុងកអាវ** ដូចមានចែងក្នុងចំណុច២ នៃមាត្រា៧ ។
- នៅចុង ដៃអាវទាំងសងខាង មានបំពាក់**សញ្ញាស័ក្តិលើចុងដៃអាវ** ដូចមានចែងក្នុងចំណុច៣ នៃមាត្រា៧ ។
- នៅលើហោប៉ៅអាវខាងឆ្វេង មានពាក់**មេដាយគោរមងារអ្នកឧកញ៉ា** ដូចមានចែងក្នុងចំណុច **ក** នៃមាត្រា៨ ។

**ខ-បន្ទោងខ្សែក ៖** នៅខាងក្រោមសញ្ញាស័ក្តិលើចុងកអាវ មានបំពាក់**បន្ទោងខ្សែកមាស** ត្រឹមដើមទ្រូង ដូចមានចែងក្នុងមាត្រា៩ ។

**គ-ខោ ៖** ជើងវែងពណ៌សដូចពណ៌អាវ ដេរថ្នេរបង្កប់ ចង្កេះត ជីបភ្លីខាងមុខម្ខាងពីរ និងមានហោប៉ៅចំនួនបី។ ហោប៉ៅចំហៀងពីរមានមាត់បញ្ឆិត និងហោប៉ៅខាងក្រោយមួយផ្នែកខាងស្តាំ។ ហោប៉ៅខាងក្រោយដេរបង្កប់ មិនមានគម្រប មានចោះរន្ធសម្រាប់ដាក់ឡេវ ដែលមានពណ៌ដូចពណ៌ខោ ។

**ឃ-ខ្សែក្រវ៉ាត់ ៖** ខ្សែក្រវ៉ាត់ធ្វើអំពីស្បែកពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់ធ្វើអំពីមាស ដែលមានរូបសញ្ញាជាអក្សរកាត់(**អ.ឱ**) អមដោយក្បាច់ភ្ញីវល្លិ៍ និងក្បាច់កញ្ចាំងព័ទ្ធជុំវិញ ។

**ង-ស្បែកជើង ៖** ស្បែកជើងឃ្លុប កខ្លី ស្បែកពណ៌ខ្មៅ មានកែងកម្ពស់ ៣០មីលីម៉ែត្រ ឬកែងរាបស្មើ និងមានស្រោមជើងពណ៌ខ្មៅពាក់កណ្តាលស្មងជើង (ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី១)។

**២-ចំពោះស្ត្រី**

**ក-អាវ ៖**

- អាវកុត កត្រង់ ដៃវែងពណ៌ស មានប៉ូលបកបិតទាំងសងខាង ដូចបុរសដែរ ប៉ុន្តែមានជីបរាងចំហោប៉ៅខាងលើចុះក្រោម តាមលក្ខណៈអាវស្ត្រី និងមានឡេវមុខរូបព្រះរាជសង្ហារពណ៌មាសចំនួនប្រាំ ។ អាវនេះ មានហោប៉ៅខាងមុខដេរបង្កប់ចំនួនបួន នៅខាងលើពីរ និងខាងក្រោមពីរ ។ ហោប៉ៅពីរខាងលើ មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធសម្រាប់ដាក់ឡេវ ដែលមានរូបព្រះរាជសង្ហារពណ៌មាស ទំហំ១៨មីលីម៉ែត្រ ។ ហោប៉ៅពីរខាងក្រោម ខិតចំហៀងចំចង្កេះទាំងសងខាងដេរបង្កប់ ដែលហោប៉ៅម្ខាងៗ មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធសម្រាប់ដាក់ឡេវ ដែលមានរូបព្រះរាជសង្ហារពណ៌មាស ទំហំ២១មីលីម៉ែត្រ ។
- នៅលើស្មាទាំងសងខាង មានបំពាក់**សញ្ញាស័ក្តិស្មា** ដូចមានចែងក្នុងចំណុច១ នៃមាត្រា៧ ។
- ចុង កអាវទាំងសងខាង មានបំពាក់**សញ្ញាស័ក្តិលើចុងកអាវ** ដូចមានចែងក្នុងចំណុច២ នៃមាត្រា៧ ។
- នៅចុង ដៃអាវទាំងសងខាង មានបំពាក់**សញ្ញាស័ក្តិលើចុងដៃអាវ** ដូចមានចែងក្នុងចំណុច៣ នៃមាត្រា៧ ។
- នៅលើហោប៉ៅអាវខាងឆ្វេង មានពាក់**មេដាយគោរមងារអ្នកឧកញ៉ា** ដូចមានចែងក្នុងចំណុច **ក** នៃមាត្រា៨ ។

**ខ-បន្ទោងខ្សែក ៖** នៅខាងក្រោមសញ្ញាស័ក្តិលើចុងកអាវ មានបំពាក់**បន្ទោងខ្សែកមាស** ត្រឹមដើមទ្រូង ដូចមានចែងក្នុងមាត្រា៩ ។

**គ-សំពត់បត់ជាមួង៖** ពណ៌បៃតងចាស់ មានសំរុងត្រឹមភ្នែកជើង សម្រាប់ប្រើជាមួយអាវកុត កត្រង់ ដៃវែង ពណ៌ស ។

**ឃ-ស្បែកជើង៖** ស្បែកជើងកែងចោត កខ្លី មានកែងកម្ពស់ ៥០មីលីម៉ែត្រ ឬកែងរាបស្មើ ស្បែកពណ៌ខ្មៅ និងមានស្រោមជើងកខ្លីពណ៌ខ្មៅ (ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី២) ។

## ផ្នែកទី២

## ឯកសណ្ឋានគោរមងារ ឧកញ៉ា

**មាត្រា ៥ .–**

ឯកសណ្ឋានគោរមងារផ្លូវការរបស់ឧកញ៉ា ត្រូវបានកំណត់ដូចខាងក្រោម ៖

**១-ចំពោះបុរស**

**ក-អាវ ៖**

- អាវកុត កត្រង់ ដៃវែងពណ៌ស មានប៉ូលបកបិតទាំងសងខាង ផែកខ្នងខាងក្រោមទាំងសងខាង មិនជីបស្មា ជីបខ្នង និងមានឡេវមុខរូបព្រះរាជសង្ហារពណ៌មាសចំនួនប្រាំពីរ និងមានទំហំ២៤មីលីម៉ែត្រ ។ អាវនេះ មានហោប៉ៅខាងមុខដេរបង្កប់ចំនួនបួន នៅខាងលើពីរ និងខាងក្រោមពីរ ។ ហោប៉ៅពីរខាងលើ មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធសម្រាប់ដាក់ឡេវដែលមានរូបព្រះរាជសង្ហារពណ៌មាសទំហំ១៨មីលីម៉ែត្រ ។ ហោប៉ៅពីរខាងក្រោមដេរបង្កប់ ដែលហោប៉ៅម្ខាងៗ មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធដាក់ឡេវរូបព្រះរាជសង្ហារពណ៌មាស ទំហំ២១មីលីម៉ែត្រ ។
- នៅលើស្មាទាំងសងខាង មានបំពាក់**សញ្ញាស័ក្តិស្មា** ដូចមានចែងក្នុងចំណុច១ នៃមាត្រា៧ ។
- ចុង កអាវទាំងសងខាង មានបំពាក់**សញ្ញាស័ក្តិលើចុងកអាវ** ដូចមានចែងក្នុងចំណុច២ នៃមាត្រា៧។
- នៅចុង ដៃអាវទាំងសងខាង មានបំពាក់**សញ្ញាស័ក្តិលើចុងដៃអាវ** ដូចមានចែងក្នុងចំណុច៣ នៃមាត្រា៧ ។
- នៅលើហោប៉ៅអាវខាងឆ្វេង មានពាក់**មេដាយគោរមងារឧកញ៉ា** ដូចមានចែងក្នុងចំណុច **ខ** នៃមាត្រា៨ ។

**ខ-បន្តោងខ្សែក ៖** នៅខាងក្រោមសញ្ញាស័ក្តិលើចុងកអាវ មានបំពាក់**បន្តោងខ្សែកមាស** ត្រឹមដើមទ្រូង ដូចមានចែងក្នុងមាត្រា៩ ។

**គ-ខោ ៖** ជើងវែងពណ៌សដូចពណ៌អាវ ដេរថ្នេរបង្កប់ ចង្កេះត ជីបភ្លីខាងមុខម្ខាងពីរ និងមានហោប៉ៅចំនួនបី។ ហោប៉ៅចំហៀងពីរមានមាត់បញ្ឆិត និងហោប៉ៅខាងក្រោយមួយផ្នែកខាងស្តាំ។ ហោប៉ៅខាងក្រោយដេរបង្កប់ មិនមានគម្រប មានចោះរន្ធសម្រាប់ដាក់ឡេវ ដែលមានពណ៌ដូចពណ៌ខោ ។

**ឃ-ខ្សែក្រវ៉ាត់ ៖** ខ្សែក្រវ៉ាត់ធ្វើអំពីស្បែកពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់ធ្វើអំពីមាស ដែលមានរូបសញ្ញាជាអក្សរកាត់ (**ឧ**) អមដោយក្បាច់ភ្ញីវល្លិ៍ និងក្បាច់កញ្ចាំងព័ទ្ធជុំវិញ ។



ហ្វ

**ង-ស្បែកជើង ៖** ស្បែកជើងឃ្លុប កខ្លី ស្បែកពណ៌ខ្មៅ មានកែងកម្ពស់៣០មីលីម៉ែត្រ ឬកែងរាបស្មើ និងមានស្រោមជើងពណ៌ខ្មៅពាក់កណ្តាលស្មងជើង (ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី៣)។

**២-ចំពោះស្ត្រី**

**ក-អាវ ៖**

- អាវកុត កត្រង់ ដៃវែងពណ៌ស មានប៉ូលបកបិតទាំងសងខាង ដូចបុរសដែរ ប៉ុន្តែមានជីបរាងចំហោប៉ៅខាងលើចុះក្រោម តាមលក្ខណៈអាវស្ត្រី និងមានឡេវមុខរូបព្រះរាជសង្ហារពណ៌មាសចំនួនប្រាំ ។ អាវនេះ មានហោប៉ៅខាងមុខដេរបង្កប់ចំនួនបួន នៅខាងលើពីរ និងខាងក្រោមពីរ ។ ហោប៉ៅពីរខាងលើ មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធសម្រាប់ដាក់ឡេវ ដែលមានរូបព្រះរាជសង្ហារពណ៌មាស ទំហំ១៨មីលីម៉ែត្រ ។ ហោប៉ៅពីរខាងក្រោមខិតចំហៀងចំចង្កេះទាំងសងខាង ដេរបង្កប់ ដែលហោប៉ៅម្ខាងៗ មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធសម្រាប់ដាក់ឡេវ ដែលមានរូបព្រះរាជសង្ហារពណ៌មាស ទំហំ២១មីលីម៉ែត្រ ។
- នៅលើស្មាទាំងសងខាង មានបំពាក់**សញ្ញាស័ក្តិស្មា** ដូចមានចែងក្នុងចំណុច១ នៃមាត្រា៧ ។
- ចុង កអាវទាំងសងខាង មានបំពាក់**សញ្ញាស័ក្តិលើចុងកអាវ** ដូចមានចែងក្នុងចំណុច២ នៃមាត្រា៧។
- នៅចុង ដៃអាវទាំងសងខាង មានបំពាក់**សញ្ញាស័ក្តិលើចុងដៃអាវ** ដូចមានចែងក្នុងចំណុច៣ នៃមាត្រា៧ ។
- នៅលើហោប៉ៅអាវខាងឆ្វេង មានពាក់**មេដាយគោរមងារឧកញ៉ា** ដូចមានចែងក្នុងចំណុច **គ** នៃមាត្រា៨ ។

**ខ-បន្តោងខ្សែក ៖** នៅខាងក្រោមសញ្ញាស័ក្តិលើចុងកអាវ មានបំពាក់**បន្តោងខ្សែកមាស** ត្រឹមដើមទ្រូង ដូចមានចែងក្នុងមាត្រា៩ ។

**គ-សំពត់បត់ជាឬង ៖** ពណ៌ខៀវចាស់ មានសំរុងត្រឹមភ្នែកជើង សម្រាប់ប្រើជាមួយអាវកុត កត្រង់ ដៃវែង ពណ៌ស ។

**ឃ-ស្បែកជើង ៖** ស្បែកជើងកែងចោត កខ្លី មានកែងកម្ពស់ ៥០មីលីម៉ែត្រ ឬកែងរាបស្មើ ស្បែកពណ៌ខ្មៅ និងមានស្រោមជើងកខ្លីពណ៌ខ្មៅ (ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី៤) ។

## ជំពូកទី៣
## សញ្ញាស័ក្តិ មេដាយ និងបន្តោងខ្សែក

**មាត្រា ៦ .—**

សញ្ញាស័ក្តិ មេដាយ និងបន្តោងខ្សែក សម្រាប់ពាក់លើឯកសណ្ឋានគោរមងារអ្នកឧកញ៉ា និងឧកញ៉ា ត្រូវបានប្រើប្រាស់ទៅតាមអតីតភាព នៃការទទួលបានគោរមងារនីមួយៗ ។



ឞ

## ផ្នែកទី១
## សញ្ញាស័ក្តិ

**មាត្រា ៧ .–**

សញ្ញាស័ក្តិសម្រាប់ពាក់លើឯកសណ្ឋានគោរមងារអ្នកឧកញ៉ា និងឧកញ៉ា រួមមាន សញ្ញាស័ក្តិស្មា សញ្ញាស័ក្តិចុងករអាវ និងសញ្ញាស័ក្តិចុងដៃអាវ ។

**១-សញ្ញាស័ក្តិស្មា ៖** មានផ្ទៃពណ៌បៃតងចាស់ ទំហំ៦.២សង់ទីម៉ែត្រ គុណនឹង ១៣.២សង់ទីម៉ែត្រ មានរូបសញ្ញាជាអក្សរកាត់ពណ៌មាស (**អ.ឧ**)សម្រាប់សម្គាល់គោរមងារ**អ្នកឧកញ៉ា** និង(**ឧ**)សម្រាប់សម្គាល់គោរមងារ**ឧកញ៉ា** លំអដោយក្បាច់ភ្ញីវល្លិ៍ពណ៌មាស និងមានខ្សែរឹមពណ៌មាសនៅអមជុំវិញ ។

**២-សញ្ញាស័ក្តិចុងករអាវ ៖** មានផ្ទៃពណ៌បៃតងចាស់ ទំហំ៤សង់ទីម៉ែត្រ គុណនឹង ៨សង់ទីម៉ែត្រ មានរូបសញ្ញាជាអក្សរកាត់ពណ៌មាស (**អ.ឧ**)សម្រាប់សម្គាល់គោរមងារ**អ្នកឧកញ៉ា** និង(**ឧ**)សម្រាប់សម្គាល់គោរមងារ**ឧកញ៉ា** លំអដោយក្បាច់ភ្ញីវល្លិ៍ពណ៌មាស និងមានខ្សែរឹមពណ៌មាសនៅអមជុំវិញ ។

**៣-សញ្ញាស័ក្តិចុងដៃអាវ ៖** មានផ្ទៃពណ៌បៃតងចាស់ ទំហំ៩.៨សង់ទីម៉ែត្រ គុណនឹង ៣២សង់ទីម៉ែត្រ លំអដោយក្បាច់ភ្ញីវល្លិ៍ពណ៌មាស និងមានខ្សែរឹមពណ៌មាសនៅអមជុំវិញ ។ រីឯសញ្ញាស័ក្តិចុងដៃអាវ សម្រាប់សម្គាល់គោរមងារ**អ្នកឧកញ៉ា** មានខ្សែរឹមពណ៌មាសព័ទ្ធពីរជាន់លើក្បាច់ភ្ញីវល្លិ៍ពណ៌មាស ។

## ផ្នែកទី២
## មេដាយ

**មាត្រា ៨ .–**

មេដាយសម្រាប់ពាក់លើឯកសណ្ឋានគោរមងារអ្នកឧកញ៉ា និងឧកញ៉ា មានបីប្រភេទ ៖

**ក-មេដាយមាស ៖ មានរាងស្លឹកពោធិ៍បញ្ឈរ** លំអដោយក្បាច់ពងត្រី និងក្បាច់កញ្ចាំងព័ទ្ធជុំវិញ ទំហំ ៥.២សង់ទីម៉ែត្រ គុណនឹង ៦.៧សង់ទីម៉ែត្រ មានរូបសញ្ញាជាអក្សរកាត់ធ្វើអំពីមាស(**អ.ឧ**) សម្រាប់សម្គាល់គោរមងារ**អ្នកឧកញ៉ា** និង(**ឧ**)សម្រាប់សម្គាល់គោរមងារ**ឧកញ៉ា** ។ មេដាយនេះប្រើសម្រាប់អ្នកមានគោរមងារ**ឧកញ៉ា** ដែលមានអតីតភាពចាប់ពី១០ឆ្នាំឡើងទៅ ។ ដោយឡែកចំពោះគោរមងារ**អ្នកឧកញ៉ា** ត្រូវប្រើប្រាស់មេដាយនេះទាំងអស់ ដោយពុំមានកំណត់អតីតភាពនោះទេ ។

**ខ-មេដាយប្រាក់ ៖ មានរាងស្លឹកពោធិ៍បញ្ឈរ** លំអដោយក្បាច់ពងត្រី និងក្បាច់កញ្ចាំងព័ទ្ធជុំវិញ ទំហំ ៥.២សង់ទីម៉ែត្រ គុណនឹង ៦.៧សង់ទីម៉ែត្រ មានរូបសញ្ញាជាអក្សរកាត់ធ្វើអំពីប្រាក់(**ឧ**) សម្រាប់សម្គាល់គោរមងារ**ឧកញ៉ា** ដែលមានអតីតភាពចាប់ពី០៥ឆ្នាំ ដល់១០ឆ្នាំ ។

**គ-មេដាយសំរឹទ្ធ ៖ មានរាងស្លឹកពោធិ៍បញ្ឈរ** លំអដោយក្បាច់ពងត្រី និងក្បាច់កញ្ចាំងព័ទ្ធជុំវិញ ទំហំ ៥.២សង់ទីម៉ែត្រ គុណនឹង ៦.៧សង់ទីម៉ែត្រ មានរូបសញ្ញាជាអក្សរកាត់ពណ៌សំរឹទ្ធ(**ឧ**) សម្រាប់សម្គាល់គោរមងារ**ឧកញ៉ា** ដែលមានអតីតភាពក្រោម០៥ឆ្នាំ ។

## ផ្នែកទី៣
## បន្ទោងខ្សែក

**មាត្រា ៩ ._**

បន្ទោងខ្សែកសម្រាប់ពាក់លើឯកសណ្ឋានគោរមងារផ្លូវការ អ្នកឧកញ៉ា និងឧកញ៉ា គឺប្រើបន្ទោងខ្សែកមាស មានរាងស្លឹកពោធិ៍សំយុងចុះ និងផ្នែកខាងចុងរាងបត់ទៅខាងស្តាំបន្តិច លំអរដោយក្បាច់ពងត្រី និងក្បាច់កញ្ចាំងព័ទ្ធជុំវិញ មានទំហំ៦.៩សង់ទីម៉ែត្រ គុណនឹង ៩សង់ទីម៉ែត្រទាំងអស់គ្នា។ បន្ទោងខ្សែកសម្រាប់ពាក់លើឯកសណ្ឋានគោរមងារអ្នកឧកញ៉ា មានរូបសញ្ញាអក្សរកាត់(អ.ឧ) និងសម្រាប់ពាក់លើឯកសណ្ឋានគោរមងារឧកញ៉ា មានរូបសញ្ញាអក្សរកាត់(ឧ) ។

## ជំពូកទី៤
## ផ្នែកទី១
## ការផ្តល់

**មាត្រា ១០ ._**

ឯកសណ្ឋានគោរមងារផ្លូវការ សញ្ញាស័ក្តិ មេដាយ និងបន្ទោងខ្សែក សម្រាប់ពាក់លើឯកសណ្ឋានគោរមងារអ្នកឧកញ៉ា និងឧកញ៉ា ត្រូវបានពិនិត្យ រៀបចំ និងផ្តល់ជូនតាមគោលការណ៍កំណត់របស់សមាគមមូលនិធិសម្តេចតេជោ ដើម្បីអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា ។

## ផ្នែកទី២
## ការប្រើប្រាស់ឯកសណ្ឋាន

**មាត្រា ១១ ._**

ឯកសណ្ឋានគោរមងារផ្លូវការ អ្នកឧកញ៉ា និងឧកញ៉ាទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា និងជាប្រធាន អនុប្រធាន សមាជិកក្រុមប្រឹក្សាភិបាល និងសមាជិកសមាគមមូលនិធិ សម្តេចតេជោ ដើម្បីអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា សម្រាប់ប្រើប្រាស់ក្នុងពេលចូលរួមក្នុងពិធីបុណ្យជាតិ បុណ្យប្រពៃណីជាតិ និងពិធីផ្លូវការផ្សេងៗ ។

## ជំពូកទី៥
## ទោសប្បញ្ញត្តិ

**មាត្រា ១២ ._**

ជនណាដែលបានប្រើប្រាស់ ឬក្លែងបន្លំឯកសណ្ឋានគោរមងារផ្លូវការ សញ្ញាស័ក្តិ មេដាយ និងបន្ទោងខ្សែក សម្រាប់ពាក់លើឯកសណ្ឋានគោរមងារអ្នកឧកញ៉ា និងឧកញ៉ា ត្រូវផ្តន្ទាទោសទៅតាមច្បាប់ជាធរមាន។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា ១៣ .—**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៤ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ១១កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី ១

នៃអនុក្រឹត្យលេខ..២២៦..អនក្រ.បក.......... ចុះថ្ងៃទី.១៥.ខែវិច្ឆិកា ឆ្នាំ២០២១
ស្តីពីឯកសណ្ឋាន សញ្ញាស័ក្តិ មេដាយ និងបន្តោងខ្សែក សម្រាប់គោរមងារផ្លូវការ
របស់អ្នកឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា

## គំរូឯកសណ្ឋានគោរមងារអ្នកឧកញ៉ា

**១.ចំពោះ បុរស**

**អាវកុត ក្រវាត់ និងខោ**

ពីមុខ



ពីក្រោយ



ខ្សែក្រវ៉ាត់បុរស



ពីមុខ



ពីក្រោយ



ស្បែកជើងបុរស



ស្រោមជើងបុរស



# ឧបសម្ព័ន្ធទី ២

នៃអនុក្រឹត្យលេខ..២៤៦..អនក្រ.បក............ ចុះថ្ងៃទី.១៥..ខែវិច្ឆិកា.ឆ្នាំ២០២១
ស្តីពីឯកសណ្ឋាន សញ្ញាស័ក្តិ មេដាយ និងបន្ទោងខ្សែក សម្រាប់គោរមងារផ្លូវការ
របស់អ្នកឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា

## គំរូឯកសណ្ឋានគោរមងារអ្នកឧកញ៉ា

**២.ចំពោះ ស្ត្រី**

**អាវក្រុត កត្រង់ និងសំពត់ផាមួង**

ពីមុខ



ពីក្រោយ



ស្បែកជើងស្ត្រី



ពីមុខ



ពីក្រោយ



ស្រោមជើងស្ត្រី



# ឧបសម្ព័ន្ធទី ៣

នៃអនុក្រឹត្យលេខ..២២៦..អនក្រ.បក........... ចុះថ្ងៃទី.១៥.ខែវិច្ឆិកា.ឆ្នាំ២០២១
ស្តីពីឯកសណ្ឋាន សញ្ញាស័ក្តិ មេដាយ និងបន្តោងខ្សែក សម្រាប់គោរមងារផ្លូវការ
របស់ឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា

## គំរូឯកសណ្ឋានគោរមងារឧកញ៉ា

**១.ចំពោះ បុរស**

**អាវកុត ក្រវ៉ាត់ និងខោ**

ពីមុខ



ពីក្រោយ



ខ្សែក្រវ៉ាត់បុរស



ស្បែកជើងបុរស



ពីមុខ



ពីក្រោយ



ស្រោមជើងបុរស



## ឧបសម្ព័ន្ធទី ៤

នៃអនុក្រឹត្យលេខ...២២៦..អនក្រ..បក.......... ចុះថ្ងៃទី.១៥..ខែវិច្ឆិកា ឆ្នាំ២០២១
ស្តីពីឯកសណ្ឋាន សញ្ញាស័ក្តិ មេដាយ និងបន្ទោងខ្សែក សម្រាប់គោរមងារផ្លូវការ
របស់ឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា

**គំរូឯកសណ្ឋានគោរមងារឧកញ៉ា**

**២. ចំពោះ ស្ត្រី**

**អាវកុត កាត្រង់ និងសំពត់ផាមួង**

ពីមុខ



ពីក្រោយ



ស្បែកជើងស្ត្រី



ពីមុខ



ពីក្រោយ



ស្រោមជើងស្ត្រី



# ឧបសម្ព័ន្ធទី ៥

នៃអនុក្រឹត្យលេខ.២២៦.អនក្រ.បក ចុះថ្ងៃទី.១៥..ខែ.វិច្ឆិកា....ឆ្នាំ២០២១
ស្តីពីឯកសណ្ឋាន សញ្ញាស័ក្តិ មេដាយ បន្តោងខ្សែក និងខ្សែក្រវ៉ាត់ សម្រាប់គោរមងាផ្លូវការ
របស់អ្នកឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា

**គំរូសញ្ញាស័ក្តិ មេដាយ បន្តោងខ្សែក និងខ្សែក្រវ៉ាត់សម្រាប់**
**អ្នកឧកញ៉ា**


មេដាយ


បន្តោងខ្សែក


ស័ក្តិលើស្មា


ស័ក្តិលើ កអាវ


ស័ក្តិចុងដៃអាវ


ក្បាលខ្សែក្រវ៉ាត់

# ឧបសម្ព័ន្ធទី ៦

នៃអនុក្រឹត្យលេខ១២២៦.អនក្រ.បក ចុះថ្ងៃទី..១៥...ខែវិច្ឆិកា.....ឆ្នាំ២០២១
ស្ដីពីឯកសណ្ឋាន សញ្ញាស័ក្តិ មេដាយ បន្ទោងខ្សែក និងខ្សែក្រវ៉ាត់ សម្រាប់គោរមងារផ្លូវការ
របស់ឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា

## គំរូសញ្ញាស័ក្តិ មេដាយ បន្ទោងខ្សែក និងខ្សែក្រវ៉ាត់សម្រាប់
## ឧកញ៉ា




មេដាយ


បន្ទោងខ្សែក


ស័ក្តិលើស្មា


ស័ក្តិលើ កអាវ


ស័ក្តិចុងដៃអាវ


ក្បាលខ្សែក្រវ៉ាត់

# ឧបសម្ព័ន្ធទី ៧

នៃអនុក្រឹត្យលេខ...២២៦..អនក្រ.បក.......... ចុះថ្ងៃទី.១៥.ខែវិច្ឆិកា.ឆ្នាំ២០២១
ស្តីពីឯកសណ្ឋាន សញ្ញាស័ក្តិ មេដាយ និងបន្ទោងខ្សែក សម្រាប់គោរមងារផ្លូវការ
របស់អ្នកឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា

**គំរូឯកសណ្ឋានគោរមងារអ្នកឧកញ៉ា**



# ឧបសម្ព័ន្ធទី ៨

នៃអនុក្រឹត្យលេខ...២២៦ អនក្រ.បក......... ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១
ស្តីពីឯកសណ្ឋាន សញ្ញាស័ក្តិ មេដាយ និងបន្ទោងខ្សែក សម្រាប់គោរពមងារផ្លូវការ
របស់អ្នកឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា

**គំរូឯកសណ្ឋានគោរពមងារអ្នកឧកញ៉ា**



# ឧបសម្ព័ន្ធទី ៩

នៃអនុក្រឹត្យលេខ...២២៦.អនក្រ.បក......... ចុះថ្ងៃទី១៥.ខែវិច្ឆិកា ឆ្នាំ២០២១
ស្តីពីឯកសណ្ឋាន សញ្ញាស័ក្តិ មេដាយ និងបន្តោងខ្សែក សម្រាប់គោរមងារផ្លូវការ
របស់ឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា

**គំរូឯកសណ្ឋានគោរមងារឧកញ៉ា**



## ឧបសម្ព័ន្ធទី ១០

នៃអនុក្រឹត្យលេខ...២២៦ អនក្រ.បក......... ចុះថ្ងៃទី.១៥ ខែវិច្ឆិកា ឆ្នាំ២០២១
ស្តីពីឯកសណ្ឋាន សញ្ញាស័ក្តិ មេដាយ និងបន្ទោងខ្សែក សម្រាប់គោរមងារផ្សេងៗ
របស់ឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា

**គំរូឯកសណ្ឋានគោរមងារឧកញ៉ា**

